**កោះសន្តិភាព** ឆ្នាំទី៤២ លេខ៦៧១៥ ថ្ងៃព្រហស្បតិ៍ ទី៣០ ខែកក្កដា ឆ្នាំ២០០៩



ទិដ្ឋភាពគ្រួសារពលរដ្ឋទ័លក្រកំពុងចិតក្ដួចសំរាប់លាយបាយ (រូបថត សំរោង)

# គ្រួសារទាហានកូនច្រើនជីវភាពខ្វះខាតចូលព្រៃរកក្ដួចលាយបាយហូប

ខេត្តឧត្តរមានជ័យ : គ្រួសារយោធានៅព្រំដែនជាំសាងាំដែលមានកូនច្រើន ហើយជីវភាពខ្វះខាតផង កំពុងប្រឈមមុខនឹងការលំបាកពីបញ្ហាស្បៀងបាននាំកូនចៅដើរចូលទៅក្នុងព្រៃ ដើម្បីរកជីកមើមក្ដួចយកមកលាយបាយហូបគួរឱ្យអាណិតណាស់ ។

បើនិយាយពីក្ដួចលាយបាយនេះ វាបានធ្វើឱ្យយើងគ្រប់គ្នានឹកឃើញទៅដល់សម័យ ប៉ុល ពត ដែលពួកវាបង្ខំឱ្យយើងធ្វើការគ្មានពេលឈប់សំរាកហើយអាហារមិនគ្រប់គ្រាន់ ទទួលបានតែបបរប៉ុន្មានវែកប៉ុណ្ណោះ ។

មកដល់ពេលនេះ អ្នកខ្លះភ្លេចសម្លត្រកួនទៅហើយ បែរជាគ្រួសារមួយនេះទៅជារកក្ដួចមកលាយជាមួយបាយបង្គ្រប់ទៅវិញ។ តើមូលហេតុអ្វីដែលធ្វើឱ្យគ្រួសារមួយនេះហូបក្ដួច? គ្រួសារនេះបុរសជាប្ដីឈ្មោះ ស្រីល រ៉ា អាយុ៤០ឆ្នាំ ជាកងទ័ពក្នុង

កងល្បាតលេខ៤០៣ ឈរជើងនៅចំណុចច្រកជាំសងាំ មានប្រពន្ធឈ្មោះគង់ ឈីម អាយុ៣៦ឆ្នាំ មានកូនចំនួន៨នាក់ និងមានផ្ទៃពោះកូនទី៩ គំរប់៨ខែផងដែរ រស់នៅក្នុងភូមិអណ្តូង៣ ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

ព្រឹកថ្ងៃទី២៨ កក្កដា អ្នកយកព័ត៌មានកោះសន្តិភាព បានទៅដល់លំនៅឋាន បានឃើញក្រុមគ្រួសារនេះកំពុងអង្គុយជុំគ្នាចិតមើមក្តួចមួយកំភ្លូសធំនៅមុខផ្ទះរបស់ខ្លួនយ៉ាងស្រងូតស្រងាត់ជាទីបំផុត ។

តាមការឱ្យដឹងពីស្រ្តីជាម្តាយឈ្មោះ គង់ ឈីម បានឱ្យកោះសន្តិភាពដឹងថា កាលពីមុនរូបគាត់រស់នៅភូមិក្រាំ ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ។ ដោយសារការរស់នៅទីនោះមានជីវភាពខ្វះខាតពេក គាត់ក៏បានសំរេចចិត្តលក់ដីនៅស្រុកកំណើត បាន១.២០០ដុល្លារ រួចនាំកូនមករស់នៅតាមប្តីដែលធ្វើទាហានការពារព្រំដែនក្នុងភូមិអណ្តូង៣ ក្នុងឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដោយមានប្រាក់បន្តិចបន្តួចយកមកទិញដីដើម្បីរស់នៅ ដែលមានទំហំ៣០គុណ៥០ម៉ែត្រ និងពុំមានដីសំរាប់បង្កបង្កើនផល ឬដាំដំណាំផ្សេងៗនោះទេ ព្រោះរូបគាត់ទើបតែមករស់នៅបានរយៈពេលចំនួន២ឆ្នាំប៉ុណ្ណោះ។ ចំណែកប្តីរបស់គាត់កំពុងនៅបំរើក្នុងជួរកងទ័ពការពារព្រំដែន ។ ស្រ្តីរូបនេះបន្តថា រូបគាត់និងប្តីនេះ គឺជាអ្នកមេម៉ាយ និងពោះម៉ាយ ។ ប្តីគាត់ពោះម៉ាយមានកូនចំនួន៥នាក់ និងត្រូវជាបងថ្លៃ ដែលក្រោយបងស្រីបង្កើតក៏បានស្លាប់ទៅ។ រូបគាត់មានកូនចំនួន៣នាក់ ប្តីក៏ស្លាប់ចោលដែរ ខណៈនោះរូបគាត់ និងប្តីរបស់គាត់ក៏បានស្រលាញ់គ្នាធ្វើជាប្តីប្រពន្ធទៅ ដើម្បីរួមគ្នាថែរក្សាកូនក្មួយ។ បន្ទាប់មក បាននាំគ្នាមករស់នៅក្នុងខេត្ត ឧត្តរមានជ័យ ព្រោះថាប្តីទៅធ្វើជាទាហាននៅទីនេះស្រាប់ ដោយបាននាំម្តាយមានវ័យចាស់ម្នាក់មករស់នៅជាមួយផងដែរ ។



គ្រួសារកងទ័ពនេះកំពុងប្រឹងរស់ទាំងខ្វះស្បៀងអាហារ (រូបថត សំណាង)

បន្ទាប់ពីបានមករស់នៅទីនេះ ដោយរូបគាត់មានកូនច្រើនពេក រហូតទៅដល់ចំនួន៨នាក់ផង រីឯប្តីក៏ជាប់រវល់ការពារទឹកដីនៅព្រំប្រទល់ខ្មែរ-សៀមទៀត ទើបរូបគាត់ជាស្ត្រីមេផ្ទះ ឃើញជីវភាពខ្វះខាតបែបនេះ ក៏សំរេចចិត្តនាំកូនតូចៗដើរចូលទៅក្នុងព្រៃរកជីកមើមក្តួចយកមកលាយបាយហូបទើបគ្រប់គ្រាន់។ គាត់រៀបរាប់ថា មើមក្តួចនេះមុនពេលលាយបាយបានគឺត្រូវចិត្តឱ្យស្តើង រួចយកទៅត្រាំទឹកអស់រយៈពេលពី១ទៅ២ថ្ងៃអស់ជាតិពុល ទើបយកមកលាងទឹកឱ្យស្អាត រួចយកទៅចំអិនដាំលាយជាមួយនឹងបាយ ។

គាត់បន្តទៀតថា ដោយសារតែគ្រួសាររបស់គាត់មានមាត់ច្រើនលើសលប់ពេក និងមិនមានដីធ្វើស្រែចំការដូចគេទើបទីទ័លក្រយ៉ាងនេះ។ រូបគាត់សូមអំពាវនាវទៅដល់សប្បុរសជននានាមេត្តាជួយរូបគាត់ និងកូនៗផង។ ជាពិសេសគាត់សំណូមពរសុំមកសម្តេចតេជោ ហ៊ុន សែន និងលោកជំទាវសូមមេត្តាជួយកូនចៅបានដីធ្វើស្រែចំការ និងជំនួយឧបត្ថម្ភនានាសង្គ្រោះភាពតោកយ៉ាកនេះផង។